# ជំនួយឥតសំណងរបស់ជប៉ុនសម្រាប់គម្រោងទ្រង់ទ្រាយតូច
# សន្តិសុខមនុស្សជាតិ( គូសាណូណិ )
## គោលការណ៍ណែនាំ

## ១. សេចក្តីផ្តើម

បង្កើតឡើងនៅឆ្នាំ១៩៩១ ជំនួយឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ **(គូសាណូណិ)** ផ្តល់ជំនួយឧបត្ថម្ភឥតសំណងដល់អាជ្ញាធរមូលដ្ឋាន អង្គការក្រៅរដ្ឋាភិបាល ស្ថាប័នសុខាភិបាល សាលារៀន និង អង្គការមិនស្វែងរកកម្រៃទាំងឡាយ ដើម្បីអនុវត្តន៍គម្រោងអភិវឌ្ឍន៍នានានៅតាមកម្រិតសហគមន៍មូលដ្ឋានជនបទ។ នៅឆ្នាំ២០០៣ ពាក្យ "សន្តិសុខមនុស្សជាតិ" ត្រូវបានបន្ថែមដើម្បីឲ្យស្របនឹងគោលគំនិតដែលមិនគ្រាន់តែជួយជំរុញបុគ្គលនិងសហគមន៍ឲ្យម្ចាស់ការលើខ្លួនឯងប៉ុណ្ណោះទេ ប៉ុន្តែក៏ដើម្បីការពារប្រជាជនពីកត្តាជាច្រើនដែលគំរាមកំហែងដោយផ្ទាល់ដល់ជីវភាពរស់នៅ ការចិញ្ចឹមជីវិត និងសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិផងដែរ។

## ២. ស្ថាប័នមានសិទ្ធិទទួលជំនួយ

១. អង្គការក្រៅរដ្ឋាភិបាល (ជាតិ និង អន្តរជាតិ)

២. អាជ្ញាធរមូលដ្ឋាន ដូចជា មន្ទីរ (ក្រសួងមិនមានសិទ្ធិដាក់ពាក្យសុំទេ)

៣. អង្គការមិនស្វែងរកកម្រៃនានាមានដូចជា ស្ថាប័នសុខាភិបាលនានា

ស្ថាប័នដាក់ពាក្យសុំត្រូវមានបទពិសោធន៍ការងារនៅក្នុងប្រទេសកម្ពុជាយ៉ាងតិចបំផុតពីរ (២) ឆ្នាំនៅក្នុងវិស័យដែលបានលើកគម្រោងសំណើរ។ ស្ថាប័នដាក់ពាក្យសុំក៏តម្រូវឲ្យបង្ហាញពីសមត្ថភាព និងបទពិសោធន៍ពីមុនមកក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ បុគ្គលិក និងគម្រោងផ្សេងៗ។

**(*) បុគ្គល និង អង្គការស្វែងរកប្រាក់កម្រៃ មិនមានសិទ្ធិក្នុងការដាក់ពាក្យឡើយ។**

## ៣. វិស័យនៃគម្រោង

១. គម្រោងទាំងឡាយណាដែលមានគោលដៅជាគុណប្រយោជន៍សម្រាប់ប្រជាជននៅតាមសហគមន៍ និងឆ្លើយតបចំពោះតម្រូវការជាមូលដ្ឋានរបស់មនុស្សជាតិ គឺមានសិទ្ធិទទួលជំនួយឧបត្ថម្ភពីគ្រោងការណ៍របស់"គូសាណូណិ"។ សម្រាប់ជាកម្មវត្ថុយោង គម្រោងក្នុងវិស័យខាងក្រោមរាប់ថាបានទទួលការអនុវត្តន៍ក្នុងចំនួនច្រើនជាងគេៈ

(១) ការអប់រំកម្រិតមូលដ្ឋាន

(២) សុខាភិបាល និង ការថែទាំវេជ្ជសាស្ត្រ

(៣) ប្រព័ន្ធធារាសាស្ត្រទ្រង់ទ្រាយតូច

(៤) ការអភិវឌ្ឍជនបទរួមទាំងផ្លូវថ្នល់ និង ស្ពាន

(៥) ការផ្គត់ផ្គង់ទឹកស្អាត និង អនាម័យ (*)

(៦) ការបណ្តុះបណ្តាលវិជ្ជាជីវៈ

(៧) សុខុមាលភាពសង្គម (ឧ. ការផ្គត់ផ្គង់ជនងាយរងគ្រោះ ជនពិការ ។ល។)

(៨) សកម្មភាពដោះមីនមនុស្សធម៌

(*)នៅក្នុងគម្រោងផ្នែកផ្គត់ផ្គង់ទឹកស្អាត ផ្នែកអនាម័យ ជីកអណ្តូងទឹក មានអាទិភាពទាប ក្រោមគម្រោង "គូសាណូណិ"

ដោយសារតែត្រូវប្រឈមនឹងហានិភ័យនៃសារធាតុបំពុលគីមីជាដើម។ល។

២. គម្រោងនៅក្នុងវិស័យខាងក្រោមនេះមិនមានសិទ្ធិទទួលជំនួយទេៈ

(១) សកម្មភាពពាណិជ្ជកម្ម

(២) សកម្មភាពវប្បធម៌ និង កីឡា

(សូមស្នើសុំជំនួយឧបត្ថម្ភឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូចផ្នែកវប្បធម៌)

(៣) ការអប់រំថ្នាក់ឧត្តមសិក្សា

## ៤. តម្លៃរបស់គម្រោង

១. ថវិកាជំនួយសម្រាប់គម្រោងនិមួយៗ នៅក្នុងឆ្នាំសារពើពន្ធឆ្នាំនេះ គឺមានចំនួន ២០លានយ៉េន (រូបិយប័ណ្ណជប៉ុន)។ ថវិកាជំនួយនេះ គិតជាដុល្លារសហរដ្ឋអាមេរិក ដោយផ្អែកលើអត្រាប្តូរប្រាក់រវាងប្រាក់យ៉េន និងប្រាក់ដុល្លារ ដែលត្រូវបានកំណត់នៅដើមឆ្នាំនៃសារពើពន្ធនៃឆ្នាំនីមួយៗ។ ព័ត៌មានលំអិត សូមប្រឹក្សាជាមួយផ្នែកសម្របសម្រួលគម្រោងគូសាណូណិរបស់ស្ថានទូតជប៉ុន។

២. ថវិកាគម្រោងដែលអាចទទួលការឧបត្ថម្ភបានរួមមានការសាងសង់សំណង់ និងការផ្គត់ផ្គង់សម្ភារៈ និងការចំណាយលើបុគ្គលិក (ដោយមិនរាប់បញ្ចូលការចំណាយលើបុគ្គលិករបស់អង្គការទទួលជំនួយ) ដែលចាំបាច់ដើម្បីឲ្យគម្រោងសម្រេចទៅបាន។ បន្ថែមពីនេះ ថ្លៃនៃការបណ្តុះបណ្តាលសម្រាប់សម្ភារៈបរិក្ខាដែលបានផ្តល់ជូន ការពង្រឹងគណៈកម្មាធិការសហគមន៍ ដូចជា គណៈកម្មាធិការគ្រប់គ្រងទឹក និងសហគមន៍កសិកម្ម ឬសកម្មភាពបង្កើនការយល់ដឹង ក៏អាចត្រូវបានគាំទ្រផងដែរនៅពេលដែលសកម្មភាពទាំងនោះទាក់ទងនឹងរបស់ជាក់ស្តែងតាំងពីពេលដើមដំបូង។

**សម្ភារៈខាងក្រោមនេះ (តាមគោលការណ៍) មិនត្រូវបានផ្តល់ជូនដោយជំនួយនេះឡើយៈ**

(១.) ការចំណាយផ្នែករដ្ឋបាលរបស់អង្គការស្នើសុំជំនួយដូចជាៈ ការជួលការិយាល័យ និងប្រាក់ខែរបស់បុគ្គលិក

(២.) ការចំណាយលើសេវាកម្មប្រតិបត្តិ ឬការថែទាំអគារ និង សម្ភារៈផ្សេងៗ

(៣.) ថវិកាបំរុង

(៤.) សកម្មភាពទទួលបានប្រាក់ចំនូល

(៥.) មុខចំណាយដូចជាៈ អាហាររូបករណ៍ ផ្ទះ និងសំលៀកបំពាក់ដែលជាកម្មសិទ្ធិរបស់បុគ្គល (លើកលែងតែករណីសង្គ្រោះបន្ទាន់សំរាប់តម្រូវការមនុស្សធម៌)

(៦.) របស់ប្រើប្រាស់ និងសម្ភារៈតូចតាច

(៧.) សៀវភៅ និង កុំព្យូទ័រផ្ទាល់ខ្លួន

(៨.) យានយន្ត (លើកលែងតែយានយន្តប្រើប្រាស់ក្នុងគោលបំណងពិសេសដូចជាៈ រថយន្តដឹកសំរាម រថយន្តពន្លត់អគ្គិភ័យ រថយន្តសង្គ្រោះបន្ទាន់ -ល-)

(៩.) ដីធ្លី និង

(១០.) ពន្ធដារ ឬ កម្រៃជើងសារធនាគារ

* ពន្ធដែលទាក់ទងនឹងការនាំចូលសម្រាប់ទំនិញដែលត្រូវបានផ្តល់ដោយ KUSANONE គួរតែត្រូវបានលើកលែងឬសងប្រាក់វិញ។ វាគឺជាទំនួលខុសត្រូវរបស់ស្ថាប័ន/អង្គការទទួលជំនួយក្នុងការត្រួតពិនិត្យទៅលើការលើកលែងពន្ធ។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងផ្នែកសម្របសម្រួលគម្រោង "គូសាណូណិ" របស់ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា។

៣. ស្ថានទូតជប៉ុន នឹងមិនគិតកម្រៃណាមួយសម្រាប់ដំណើរការនៃការដាក់ពាក្យសុំ ការពិនិត្យពាក្យសុំ និងការអនុវត្តគម្រោងគូសាណូណិឡើយ។

## ៥. រយៈពេលរបស់គម្រោង

គម្រោងដែលទទួលបានការអនុម័តហើយ ត្រូវបញ្ចប់ក្នុងរយៈពេល**មួយ(១)ឆ្នាំ**គិតចាប់ពីថ្ងៃចុះកិច្ចសន្យាផ្តល់ជំនួយ។

## ៦. របៀបនៃការដាក់ពាក្យ

១.សូមផ្ញើពាក្យស្នើសុំជំនួយនិងឯកសារចាំបាច់ផ្សេងៗទៅស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជាតាមអាស័យដ្ឋានខាងក្រោមៈ

**គោរពជូនៈ ឯកឧត្តមឯកអគ្គរាជទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា**
**ផ្នែកសម្របសម្រួលគម្រោង "គូសាណូណិ"**
**ការិយាល័យសេដ្ឋកិច្ច និងជំនួយអភិវឌ្ឍន៍ផ្លូវការ ស្ថានទូតជប៉ុន**
**# ១៩៤ មហាវិថីព្រះនរោត្តម ភ្នំពេញ**

២. ពាក្យស្នើសុំអាចរកបាននៅក្នុងគេហទំព័ររបស់ស្ថានទូតជប៉ុនៈ
(https://www.kh.emb-japan.go.jp/itpr_en/00_000067.html)

៣. **ទម្រង់នៃការដាក់ពាក្យស្នើសុំត្រូវតែភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោមៈ**

(១) លិខិតអមផ្ញើជូន **ឯកឧត្តម អ៊ូអិណុ អាត់ស៊ូស៊ី** ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

(២) សម្រង់តម្លៃច្បាប់ដើមពីអ្នកផ្គត់ផ្គង់យ៉ាងតិចចំនួនបី (៣) ក្រុមហ៊ុនដោយៈ
- លម្អិតតម្លៃសម្ភារៈ/ឧបករណ៍ តម្លៃពលកម្ម និងតម្លៃដឹកជញ្ជូន (សម្រាប់គម្រោងសាងសង់)
- រួមបញ្ចូលតម្លៃផ្លាកសញ្ញាជំនួយ
- មិនរួមបញ្ចូលពន្ធអាករលើតម្លៃបន្ថែម(VAT)
- បង្ហាញឈ្មោះរបស់ក្រុមហ៊ុន អាសយដ្ឋាន លេខទូរសព្ទ និងត្រាផ្លូវការរបស់ក្រុមហ៊ុននៅគ្រប់សន្លឹក

(៣) ផែនទីបង្ហាញទីតាំងគម្រោង និងអាសយដ្ឋាន (រួមទាំងពត៌មានដូចជាចម្ងាយពីភ្នំពេញ ឬពីក្រុងសំខាន់ណាមួយដែលនៅក្បែរ)

(៤) គំនូសប្លង់ និងបទដ្ឋានបច្ចេកទេសលម្អិតរបស់អគារ និងសម្ភារៈបរិក្ខារ (ដោយគិតទាំងទំហំ និងសម្ភារៈដែលត្រូវការ) ដោយមានត្រាផ្លូវការរបស់ក្រុមហ៊ុននៅគ្រប់សន្លឹក

(៥) គម្រោងសកម្មភាព/កាលវិភាគនៃការអនុវត្តគម្រោង

(៦) រូបថតមួយចំនួនអំពីទីតាំងគម្រោងបិទ/ភ្ជាប់លើក្រដាស់ទំហំA4 រួមនឹងការពន្យល់អំពីរូបថតនិមួយៗ

(៧) គំរូកិច្ចសន្យាលទ្ធកម្ម (អ្នកស្នើសុំ និងអ្នកផ្គត់ផ្គង់) មួយច្បាប់ ដោយមានបញ្ជាក់អំពីរយៈពេលធានា

(៨) ច្បាប់ថតចម្លងឯកសារកម្មសិទ្ធដី ឬលិខិតអនុញ្ញាតឲ្យប្រើប្រាស់ដី (សម្រាប់គម្រោងសាងសង់)

(៩) របាយការណ៍ហិរញ្ញវត្ថុ (និងរបាយការណ៍សកម្មភាព) រយៈពេលពីរ(២)ឆ្នាំចុងក្រោយ

(១០) ឯកសារគាំទ្រផ្សេងៗទៀត (ដូចជាច្បាប់ថតចម្លងឯកសារបញ្ជាក់ពីការចុះបញ្ជី កិច្ចព្រមព្រៀង អនុស្សរណៈយោគយល់គ្នា ឬឯកសារដែលទាក់ទងនឹងកិច្ចព្រមព្រៀងជាមួយក្រសួង ឬស្ថាប័នរដ្ឋាភិបាលដែលពាក់ព័ន្ធ) និង

(១១) សម្រង់តម្លៃពីសវនករឯករាជ្យយ៉ាងតិចចំនួន៣ក្រុមហ៊ុនដោយមិនរួមបញ្ចូលពន្ធអាករលើតម្លៃបន្ថែម(VAT) ប្រសិនបើគម្រោងស្នើសុំថវិកាលើសពីបីលានយ៉េន គម្រោងត្រូវតម្រូវឲ្យធ្វើសវនកម្ម។ យ៉ាងណាមិញ សម្រង់តម្លៃពីក្រុមហ៊ុនសវនកម្មមិនត្រូវបានតម្រូវនៅដំណាក់កាលដំបូងនៃសំណើរគម្រោងទេ។ សូមភ្ជាប់មកជាមួយនូវសម្រង់តម្លៃនៅពេលដែលគម្រោង និងចំនួនថវិកាស្នើសុំត្រូវបានកំណត់ជាក់លាក់ជាចុងក្រោយហើយ។

៤. ចំពោះគម្រោងសកម្មភាពដោះមីនមនុស្សធម៌ សូមទាក់ទងស្ថានទូតជប៉ុនសម្រាប់តម្រូវការបន្ថែមដែលត្រូវដាក់ក្នុងទម្រង់ពាក្យស្នើសុំ។

**៥. ពាក្យស្នើសុំមិនគ្រប់គ្រាន់ ឬមិនមានការពន្យល់សមស្រប មិនអាចទទួលបានការពិចារណាក្នុងការដាក់ពាក្យស្នើសុំឡើយ។**

## ៧. ថ្ងៃផុតកំណត់នៃការដាក់ពាក្យ

ស្ថាប័នឬអង្គការស្នើសុំជំនួយអាចដាក់ពាក្យស្នើសុំគូសាណូណិគ្រប់ពេលវេលា។ ក្នុងករណីដែលពាក្យស្នើសុំរបស់អ្នកមិនត្រូវបានពិនិត្យក្នុងគម្រោងជំនួយសម្រាប់ឆ្នាំនេះ វានឹងត្រូវបានពិនិត្យក្នុងគម្រោងសម្រាប់ឆ្នាំបន្ទាប់។ ដោយមូលហេតុនេះ គម្រោងគូសាណូណិមិនបានកំណត់កាលបរិច្ឆេទថ្ងៃឈប់ទទួលពាក្យទេ។

## ៨. ដំណើរការពិនិត្យ ការអនុមតិ និង ការអនុវត្តគម្រោង



ការចុះអង្កេតគម្រោងបណ្តោះអាសន្នដោយស្ថានទូតជប៉ុន

↓

ការផ្តល់របាយការណ៍បណ្តោះអាសន្ន

↓

ការផ្តល់របាយការណ៍បញ្ចប់

↓

ការផ្តល់របាយការណ៍សវនកម្ម

↓

ការចុះអង្កេតក្រោយបញ្ចប់គម្រោងដោយស្ថានទូតជប៉ុន

↓

ការចុះអង្កេតបន្តបន្ទាប់ដោយស្ថានទូតជប៉ុន
**(២ឆ្នាំបន្ទាប់ពីការបញ្ចប់គម្រោង)**

## ៩. លក្ខខ័ណ្ឌ និង បទបញ្ញត្តិ

### ១. កិច្ចសន្យាជំនួយ

កិច្ចសន្យាជំនួយមានដាក់ចំណងជើងរបស់គម្រោង ឈ្មោះរបស់អង្គការទទួលជំនួយ សិទ្ធិ និងកាតព្វកិច្ចរបស់ភាគីនីមួយៗ ចំនួនថវិកាអតិបរមាដែលនឹងផ្តល់សម្រាប់ការអនុវត្តគម្រោង និង ចុះកាលបរិច្ឆេទបញ្ចប់គម្រោង។

### ២. ការប្រើប្រាស់ជំនួយ

(១) ជំនួយត្រូវតែបានប្រើប្រាស់ដោយត្រឹមត្រូវ និង សម្រាប់តែការទិញទំនិញ និង/ឬ សេវាកម្មដែលចាំបាច់សម្រាប់គម្រោងដែលទទួលបានការអនុម័ត។

(២) មានការធ្វើប្រតិបត្តិការនិងការថែទាំត្រឹមត្រូវក្នុងកំឡុងពេលប្រតិបត្តិនិងបន្ទាប់ពីបញ្ចប់គម្រោង។

*អង្គការទទួលជំនួយដែលប្រើជំនួយឥតសំណងតាមរបៀបផ្សេងទៀតក្រៅពីបានបញ្ជាក់នៅក្នុងកិច្ចសន្យាឬខកខានមិនបានរាយការណ៍អំពីវឌ្ឍនភាពការអនុវត្តនិងផលប៉ះពាល់នៃគម្រោងអាចត្រូវបានស្នើសុំឱ្យសងប្រាក់ជំនួយវិញ។*

### ៣. ការបើកគណនីធនាគារដាច់ដោយឡែក

បន្ទាប់ពីការយល់ព្រមនិងការចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយស្ថាប័ន/អង្គការទទួលជំនួយនឹងតម្រូវឲ្យបើកគណនីធនាគារដាច់ដោយឡែកពីគណនីធនាគារផ្សេងទៀតដែលប្រើសម្រាប់ការចំណាយប្រតិបត្តិការរបស់ស្ថាប័ន/អង្គការ ឬគម្រោងផ្សេងទៀតរបស់ស្ថាប័ន/អង្គការលើការចំណាយក្នុងថវិកាជំនួយ។ វាជាការល្អ ប្រសិនបើអង្គការទទួលជំនួយអាចរៀបចំគណនេយ្យដាច់ដោយឡែកមួយសម្រាប់តែការអនុវត្តគម្រោងនេះ។

### ៤. ភាពមើលឃើញ

ដើម្បីធានាបាននូវភាពមើលឃើញនៃជំនួយឥតសំណងរបស់ប្រទេសជប៉ុនស្ថាប័ន/អង្គការទទួលជំនួយត្រូវខិតខំសហការជាមួយស្ថានទូតជប៉ុនក្នុងការអនុវត្តសកម្មភាពផ្ទាល់មួយចំនួនដូចជាការរៀបចំពិធីបើកសម្ពោធ ការដាក់បិទស្ទីកគ័រនិងភ្ជាប់ស្លាកសញ្ញាឬស្លាកសញ្ញាបង្ហាញទង់ជាតិប្រទេសជប៉ុនដាក់លើការរបស់សំភារៈនិងអគារដែលបានផ្តល់ជូន។ (គំរូឱ្យហ្សាញគឺមាននៅក្នុងស្ថានទូត)

## ៥. កាតព្វកិច្ចក្នុងការផ្ញើរបាយការណ៍

អង្គការទទួលជំនួយត្រូវតែផ្ញើរបាយការណ៍បញ្ចប់គម្រោងតាមទម្រង់ដែលបានកំណត់នៅពេលគម្រោងត្រូវបានបញ្ចប់។ សម្រាប់គម្រោងភាគច្រើន ការដាក់របាយការណ៍ប្រចាំខែនិងរបាយការណ៍បណ្តោះអាសន្នក៏ត្រូវបានទាមទារផងដែរ។

## ៦. ការផ្លាស់ប្តូរពីផែនការដើម

ដោយហេតុផលណាមួយ នៅពេលអង្គការទទួលជំនួយយល់ថាត្រូវតែធ្វើការកែប្រែផែនការគម្រោងរបស់ខ្លួន អង្គការទទួលជំនួយគួរតែពិគ្រោះជាមួយស្ថានទូត និងទទួលការយល់ព្រមមុនពេលផ្លាស់ប្តូរសំណើដើម។

## ៧.សវនកម្ម (External Audit)

(១) ជាគោលការណ៍ បន្ទាប់ពីបញ្ចប់គម្រោងស្ថាប័ន/អង្គការទទួលជំនួយត្រូវធ្វើ សវនកម្មខាងក្រៅ(External Audit) ដើម្បីផ្ទៀងផ្ទាត់ថាថវិកាសម្រាប់គម្រោងត្រូវបានប្រើប្រាស់ត្រឹមត្រូវ។ ជាគោលការណ៍ សវនកម្មខាងក្រៅត្រូវធ្វើដោយស្ថាប័ន ឬបុគ្គលដែលទទួលស្គាល់ជាផ្លូវការក្នុងការធ្វើសវនកម្មនៅក្នុងប្រទេសដែលគម្រោងត្រូវបានអនុវត្ត។

(២) សម្រាប់ថ្លៃចំណាយចាំបាច់សម្រាប់ការធ្វើសវនកម្មខាងក្រៅគឺអាចមានសិទ្ធិទទួលបានការគាំទ្រពី KUSANONE ។ ជាគោលការណ៍ ការប្រៀបធៀបតំលៃប៉ាន់ស្មានពីក្រុមហ៊ុនសវនកម្មចំនួនបីសម្រាប់ឧបករណ៍ ឬ របស់របរផ្សេងៗ គួរតែត្រូវបានអនុវត្ត។

(៣) នៅពេលបញ្ចប់គម្រោង របាយការណ៍សវនកម្មនឹងត្រូវផ្តល់ជូនទៅកាន់ស្ថាប័ន/ អង្គភាពទទួលជំនួយដោយសវនករ។ ស្ថាប័ន/អង្គភាពទទួលជំនួយចាំបាច់ត្រូវបញ្ជូនច្បាប់ចម្លងនៃរបាយការណ៍នេះទៅស្ថានទូតជប៉ុន។ របាយការណ៍នេះគួរតែមានន័យដូចខាងក្រោម:

A. ការផ្ទៀងផ្ទាត់របាយការណ៍ហិរញ្ញវត្ថុ (ចំណូល ចំណាយផ្ទាល់ ចំណាយប្រតិបត្តិការទាក់ទងនឹងគម្រោង។ល។ )
B. ការផ្ទៀងផ្ទាត់អង្គហេតុ (លទ្ធកម្មនិងការចែកចាយឧបករណ៍ ការប្រើប្រាស់ឧបករណ៍។ ល។ )
C. ការត្រួតពិនិត្យទីតាំងគម្រោង (ភ្ជាប់រូបថតទៅនឹងរបាយការណ៍)

(៤) ក្នុងករណីលើកលែងមួយចំនួន នៅកន្លែងដែលមិនមានស្ថាប័ន ឬបុគ្គលដែលទទួលស្គាល់ជាផ្លូវការក្នុងការធ្វើសវនកម្មនៅក្នុងប្រទេស នៅដែលជាកន្លែងដែលមានតម្រូវការតិចតួច ឬជាកន្លែងដែលវាមានការលំបាកខ្លាំងក្នុងការធ្វើសវនកម្មខាងក្រៅ អាចត្រូវបានលើកលែងប៉ុន្តែវិធានការជំនួសមួយចំនួនគួរតែត្រូវបានអនុវត្ត។ សម្រាប់ព័ត៌មានលម្អិតសូមពិគ្រោះជាមួយស្ថានទូតជប៉ុន។

## សម្រាប់ពត៌មានបន្ថែម

**សូមពិគ្រោះជាមួយនឹងអ្នកសម្របសម្រួលគម្រោងគូសាណូណេ របស់ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា**

សូមទាក់ទងមកកាន់៖ ផ្នែកសម្របសម្រួលគម្រោង "គូសាណូណេ"

**ការិយាល័យសេដ្ឋកិច្ច និង ជំនួយអភិវឌ្ឍន៍ផ្លូវការរបស់ស្ថានទូតជប៉ុន**

ទូរស័ព្ទលេខ: 023 217 161

អាស័យដ្ឋានអ៊ីមែល: eco.jpn@pp.mofa.go.jp

*(បានធ្វើបច្ចុប្បន្នភាព នៅខែកក្កដា ឆ្នាំ២០២៤)*